ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ:......០៥៥/១៨......ក.ប/ប្រ.ក

# ប្រកាសរួម

## ស្តីពី

## ការបង្កើតគណៈកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### និង

### រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបញ្ចប់តំណែងរាជរដ្ឋាភិបាល និងតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី ៤ នៃរដ្ឋសភា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែល ប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ .ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិ របបសន្តិសុខសង្គម
- តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

### ប្រការ ១.-

បង្កើតឱ្យមានគណៈកម្មការវេជ្ជសាស្ត្រអមបេឡាជាតិរបបសន្តិសុខសង្គម ដែលមានសមាសភាព ០៣ រូប ដូចខាងក្រោមៈ

| | |
|---|---|
| ១- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- តំណាងក្រសួងសុខាភិបាល | សមាជិក |

គណៈកម្មការនេះ ត្រូវមានសមាជិកបម្រុង ០២ រូប ដែល ០១ រូបមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ០១ រូបទៀតមកពីក្រសួងសុខាភិបាល។ សមាជិកបម្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬប្រធានស្តីទី។

ក្នុងករណីដែល ប្រធានគណៈកម្មការអវត្តមាន អនុប្រធានគណៈកម្មការត្រូវទទួលតួនាទីជាប្រធានស្តីទី។

ក្នុងករណីដែល ប្រធាន និងអនុប្រធានអវត្តមាន សមាជិកគណៈកម្មការមានសិទ្ធិអញ្ជើញសមាជិកបម្រុងចូលរួមប្រជុំ និងដឹកនាំអង្គប្រជុំ។

### ប្រការ ២.-

សមាជិកគណៈកម្មការវេជ្ជសាស្ត្រ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

សមាជិកគណៈកម្មការវេជ្ជសាស្ត្រ ត្រូវបានជ្រើសតាំងក្នុងចំណោមមន្ត្រីដែលមានវិជ្ជាជីវៈសមស្រប ខាងវេជ្ជសាស្ត្រតាមភារកិច្ចដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ។

**ប្រការ ៣.-**

គណៈកម្មការវេជ្ជសាស្ត្រ ត្រូវមានភារកិច្ចផ្តល់យោបល់ចំពោះ ការកំណត់កម្រិតនៃការបាត់បង់សមត្ថភាពការងាររបស់កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ និងផ្តល់យោបល់លើស្ថានភាព របស់មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស**។

ក្នុងករណីចាំបាច់ គណៈកម្មការវេជ្ជសាស្ត្រអាចអញ្ជើញគ្រូពេទ្យជំនាញ ឬអ្នកឯកទេសមកបំភ្លឺ បន្ទាប់ពីមានការឯកភាពពីនាយក **ប.ស.ស**។ ការចំណាយក្នុងការអញ្ជើញ គ្រូពេទ្យជំនាញ ឬអ្នកឯកទេសចូលរួមក្នុងការងារនេះ ត្រូវនៅក្នុងបន្ទុករបស់ **ប.ស.ស**។

**ប្រការ ៤.-**

សេចក្តីសម្រេច របស់គណៈកម្មការវេជ្ជសាស្ត្រ អាចយកជាការបាន លុះត្រាតែមានសម្លេងគាំទ្រភាគច្រើនដាច់ខាត។

**ប្រការ ៥.-**

លាភការមុខងាររបស់គណៈកម្មការវេជ្ជសាស្ត្រ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម។

**ប្រការ ៦.-**

បេឡាជាតិរបបសន្តិសុខសង្គម គ្រប់មន្ទីរពេទ្យ និងអង្គភាពមានសមត្ថកិច្ចត្រូវមានភារកិច្ចសហការ និងសម្របសម្រួលដើម្បីឱ្យគណៈកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គមអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ ដើម្បីជូនជ្រាប
- កាលប្បវត្តិ និងឯកសារ